# "កាណាក់ប៉ាក់ខូច"

ដោយ សំវិច្ឆា ថ្ងៃទី៩ វិច្ឆិកា ២០១១

១. ឲ្យយួនចូលស្រុកស្រេចនឹងចិត្ត ឲ្យយួនបង្ខិតព្រំសីមា
លួចកាប់បំផ្លាញព្រៃព្រឹក្សា ចុះហត្ថលេខា ព្រមនឹងយួន ។

២. សំណូកសូកប៉ាន់ ពុករលួយ លួចប្រាក់ជំនួយ យកផ្ទាល់ខ្លួន
លក់សម្បត្តិជាតិច្រើនចំនួន លក់ក្បាលឲ្យយួន ចូលត្រួតត្រា ។

៣. ដណ្តើមដីរាស្ត្រ យកទៅលក់ វីវក់ជាមួយពួកឧកញ៉ា
ធ្វើសម្បទានដី លានហិកតា កុងត្រានឹងយួន ជាងកៅឆ្នាំ ។

៤. បង្កើតម៉ាហ្វីយ៉ា បងតូចធំ មានក្រុមថ្នាំញៀន ឃាតករឆ្នាំ
ធ្វើបាបរាស្ត្រខ្មែរឲ្យរងកម្ម លួចបាញ់ លួច«ខាំ«ពីក្រោយខ្នង។

៥. ក្បត់កិច្ចព្រមព្រៀងក្រុងប៉ារីស បិទសិទ្ធិ ជាន់ជិះរាស្ត្រប្អូនបង
បំណុលពីចិនច្រើនកន្លង ធ្វើជាអាយ៉ង យួនកំហូច។

៦. រៀបរាប់ត្រួសៗ ដូចខាងលើ គឺជាអំពើ«កាណាក់ប៉ាក់ខូច»
គឺជាបក្សធំ មិនមែនតូច គឺ«ខូច»ពីលើមកដល់ក្រោម ៕




